# សួនសាធារណៈនៅក្នុងទីក្រុង តែជាកន្លែងមួយដែលផ្សារភ្ជាប់ទំនាក់ទំនងមនុស្សក្នុងសង្គម

បើទោះជាសួនសាធារណៈគឺជាកន្លែងសំខាន់សម្រាប់ការលើកកម្ពស់សហគមន៍ និងសង្គមក៏ដោយ ក៏រាជធានីភ្នំពេញនៅតែមានការខ្វះខាតសួនសាធារណៈសម្រាប់សាធារណជនទូទៅ ជាពិសេសសហគមន៍ក្រីក្រនៅទីក្រុង អាចប្រើប្រាស់បានដោយងាយស្រួល និងការទទួលបានអត្ថប្រយោជន៍ផ្សេងៗទៀត។ ករណីសិក្សាមួយចំនួនខាងក្រោមបង្ហាញពីរបៀបនៃការរៀបចំសួនសាធារណៈក្នុងទីក្រុង និងនៅសហគមន៍ក្រីក្រ ដែលអាចកែលម្អជីវភាពរស់នៅ កាត់បន្ថយឧក្រិដ្ឋកម្ម និងទទួលបានអារម្មណ៍សុវត្ថិភាព។



នៅរាជធានីភ្នំពេញទីធ្លាសាធារណៈកាន់តែតិចទៅៗ។ ការវាយតម្លៃថ្មីៗនេះ ក្នុងរាជធានីភ្នំពេញដែលបានបោះពុម្ពផ្សាយដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) បានរកឃើញថាសមាមាត្រលំហសាធារណៈក្នុងរាជធានីភ្នំពេញ បានធ្លាក់ចុះពី១,១មែត្រការ៉េ ក្នុងមនុស្សម្នាក់កំឡុងឆ្នាំ២០១៤ មកត្រឹមតែ០,៦៧ម៉ែត្រការ៉េ ក្នុងមនុស្សម្នាក់ក្នុងឆ្នាំ២០២០។ ស្ថិតិនេះដែរ ធ្វើឱ្យរាជធានីភ្នំពេញស្ថិតក្នុងលំដាប់ទាបជាងទីក្រុងផ្សេងទៀតនៅក្នុងតំបន់ ដូចជាប្រទេសសិង្ហបុរី ដែលមានសមាមាត្រជាមធ្យម ៧,០៤ម៉ែត្រការ៉េ សម្រាប់មនុស្សម្នាក់ហើយចំណែកឯទីក្រុងសេអ៊ូល ដែលមានសមាមាត្រ ១៤,៦៦ ម៉ែត្រការ៉េសម្រាប់មនុស្សម្នាក់ និងទីក្រុងហូជីមិញ ដែលជាមធ្យម១៣,៧ មែត្រការ៉េ សម្រាប់មនុស្សម្នាក់។

ទីក្រុងនៅតែបន្តការពង្រីកយ៉ាងឆាប់រហ័សនូវទីធ្លាសាធារណៈថ្មីៗភាគច្រើនបានបង្កើតឡើងសម្រាប់លំនៅឋានបុរី ហើយវាមិនផ្តល់ផលប្រយោជន៍ដល់សាធារណជនទូទៅឡើយ។ អាស្រ័យហេតុនេះ ហើយបានជាកង្វះទីធ្លាសាធារណៈបានក្លាយជាបញ្ហាមួយគួរឱ្យកត់សម្គាល់ ជាពិសេសនៅក្នុងសហគមន៍ក្រីក្របាននឹងកំពុងជួបប្រទះការខ្វះខាតទីធ្លាសាធារណៈ ឬសឹងតែគ្មានទីធ្លាសាធារណៈតែម្តង។ ទោះជាយ៉ាងណាក៏ដោយទីធ្លាសាធារណៈ គឺជាគន្លឹះសម្រាប់ជំរុញឱ្យប្រសើរឡើងនូវ

លទ្ធភាពរស់នៅរបស់សហគមន៍ក្រីក្រទាំងនោះ។ រាជធានីភ្នំពេញត្រូវតែរកវិធីដាក់បញ្ចូលទីធ្លាសាធារណៈបន្ថែម ជាពិសេសនៅក្នុងសង្កាត់ដែលជួបការលំបាក ឬកង្វះទីធ្លាសាធារណៈ។

**ទីកន្លែងសាធារណៈជួយដល់កុមារ និងមនុស្សចាស់ បង្កើនទំនុកចិត្ត និងលើកកម្ពស់សុវត្ថិភាព**

យោងតាមការប្រឹក្សានៃការរចនាបចចក្រភពអង់គ្លេស សួនសាធារណៈ និងរុក្ខជាតិបៃតងមានសារៈសំខាន់ណាស់ ព្រោះវាផ្តល់នូវបរិយាកាសសុវត្ថិភាពសម្រាប់កុមារក្នុងការលេង ដែលអាចឱ្យពួកគេរៀនសម្របខ្លួន មានសកម្មភាពច្នៃប្រឌិត និងជំរុញសកម្មភាពផ្សេងៗបន្ថែមទៀត។ ដូចគ្នានេះដែរ ប្រជាជនវ័យចំណាស់ក្នុងសង្គមក៏អាចទទួលបានអត្ថប្រយោជន៍ដល់សុខភាពពីទីធ្លាសាធារណៈផងដែរ។ លើសពីនេះទៀត ករណីសិក្សាបានបង្ហាញថាសួនបៃតងសាធារណៈតាមសហគមន៍ក្រីក្រមានឥទ្ធិពលជាវិជ្ជមានទៅលើការរស់នៅតាមសហគមន៍ក្រីក្រ ដោយកាត់បន្ថយឧក្រិដ្ឋកម្ម ការកសាងទំនុកចិត្ត និងលើកកម្ពស់ជីវភាពរបស់អាជីវករ។

ការយល់ឃើញរបស់អ្នកប្រើប្រាស់អំពីសុវត្ថិភាពនៅទីធ្លាសាធារណៈ ត្រូវបានផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងសកម្មភាពរស់នៅនៃតំបន់នោះ។ សកម្មភាពមនុស្ស និងភាពរស់រវើកបានបង្កើតនូវបរិយាកាសដែលមានសុវត្ថិភាព។ ចូរគិតអំពីអារម្មណ៍របស់មនុស្សម្នាក់ៗនៅពេលដើរកន្លែងដែលមានមនុស្សអ៊ូអរជាមួយអ្នកថ្មើរជើង មានមនុស្សហូបអាហារតាមតុចិញ្ចើមផ្លូវ ក្មេងៗលេង និងមនុស្សចាស់និយាយគ្នា។ ផ្ទុយទៅវិញចូរគិតអំពីអារម្មណ៍របស់មនុស្សម្នាក់ៗនៅពេលដើរកន្លែងដែលទំនេរ គ្មានមនុស្សដទៃ ហើយមានតែជញ្ជាំងខ្ពស់ និងទ្វារបិទ។

ដូច្នេះសកម្មភាពទាំងនោះ មានសារៈសំខាន់ណាស់ ព្រោះវាអាចទទួលបានការទាក់ទាញអ្នកប្រើប្រាស់ និងអាចជាបណ្ដាញឃ្លាំមើលធម្មជាតិ។ បណ្ដាញនេះ បានដើរតួនាទីក្នុងការបង្កើតសុខសុវត្ថិភាពដែលលើកកម្ពស់សុខុមាលភាពរបស់សង្គម។ ការបង្កើនសកម្មភាព និងភាពរស់រវើកនៃតំបន់មួយអាចមានលក្ខណៈសាមញ្ញ និងសន្សំសំចៃ ដូចជាការប្រើប្រាស់នូវដីទំនេរមួយ ដូចដែលករណីសិក្សាខាងក្រោមបានបង្ហាញ។

នៅក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២ អង្គការសកម្មភាពភាពកុមារក្រីក្រ (Child Poverty Action Lab) បានរួមសហការជាមួយអង្គការមូលនិធិប្លុកទីក្រុង (Better Block Foundation) ដើម្បីជំរុញឱ្យដីទំនេរមួយកន្លែងមានភាពសកម្ម។ ដីទំនេរត្រូវបានផ្លាស់ប្ដូរឱ្យមានការរៀបចំព្រឹត្តិការណ៍ផ្សេងៗ ដូចជា ការប្រកួតបាល់បោះ និងការបញ្ចាំងខ្សែភាពយន្ត។ តាមរយៈការផ្លាស់ប្ដូរទីធ្លាទំនេរទៅជាកន្លែងដែលមានសកម្មភាពមនុស្ស ទទួលបានលទ្ធផលល្អក្នុងការបង្កើនសុវត្ថិភាពសាធារណៈដោយមិនចាំបាច់បង្កើនកំលាំងនគបាល។

ទិន្នន័យប្រមូលបានបន្ទាប់ពីឆ្លងកាត់ការអន្តរាគមន៍បានរកឃើញថា ការរក្សាទីធ្លាសាធារណៈឱ្យមានភាពរស់រវើកនាំឱ្យមានការថយចុះនៃឧក្រិដ្ឋកម្ម។ អំពើហិង្សាបានធ្លាក់ចុះ ៥៩% បើធៀបនឹងឆ្នាំ២០១៩ ជាមួយនឹងការថយចុះ ២០% នៃការចាប់ខ្លួន។ សរុបមក នៅក្នុងតំបន់ដែលមានហានិភ័យខ្ពស់បំផុតនៅក្នុងផ្នែកល្បាតរបស់នាយកដ្ឋានប៉ូលីសបានធ្លាក់ចុះមកលេខ៤៦៣ នៅលើបញ្ជីចំណាត់ថ្នាក់ដូចគ្នា។ អន្តរាគមន៍នេះផងដែរ បានបង្ហាញពីភាពរស់រវើកក៏ដូចជាសកម្មភាពដែលសម្បូរបែបតាមទីធ្លាសាធារណៈ អាចជាគន្លឹះនៃសង្កាត់ដែលមានសុវត្ថិភាពជាងមុន។ សកម្មភាពមនុស្សនៅក្នុងសហគមន៍ដើរតួយ៉ាងសំខាន់ក្នុងការជំរុញឱ្យតំបន់មួយមានសុវត្ថិភាព។

ជាចុងក្រោយ ការរក្សាទីធ្លាសាធារណៈបានផ្ដល់ផលវិជ្ជមានសម្រាប់បរិស្ថាន ជាពិសេស កាត់បន្ថយឥទ្ធិពលកម្ដៅ កាត់បន្ថយទឹកជំនន់ និងកាត់បន្ថយការបំពុលខ្យល់ និងការបំពុលដោយសំឡេង។

## ការរួមបញ្ចូលសួនសាធារណៈចូលទៅក្នុងសហគមន៍ក្រីក្រ



យោងតាមកាលៈទេសៈបច្ចុប្បន្នការបង្កើតសួនច្បារខ្នាតធំប្រហែលជាមិនអាចធ្វើបានសម្រាប់រាជធានីភ្នំពេញនោះទេ។ ប៉ុន្តែទីធ្លាសាធារណៈបៃតងតូចៗ នៅតែអាចកសាងបានសម្រាប់ទីក្រុង។ ទីធ្លាសាធារណៈតូចៗមួយចំនួនធំអាចបែកខ្ញែកយ៉ាងទូលំទូលាយក្នុងចំណោមសង្កាត់នានាក្នុងរាជធានីភ្នំពេញដែលជាកត្តានាំឱ្យមានភាពងាយស្រួលសម្រាប់ប្រជាជន។

ដូចដែលបានបង្ហាញនៅក្នុងករណីសិក្សាខាងលើ ទីធ្លាសាធារណៈតូចៗ (PocketParks) បណ្ដោះអាសន្ន មានភាពបត់បែនក្នុងការប្រើប្រាស់ និងទាមទារការចំណាយទាប ខណៈពេលដែលរក្សាបាននូវផលវិជ្ជមានដូចគ្នា។ ដូច្នេះដំណោះស្រាយក្នុងការអនុវត្ត ក្នុងទ្រង់ទ្រាយធំ អាជ្ញាធរមូលដ្ឋានអាចចាប់ផ្ដើមដោយកំណត់អត្តសញ្ញាណដីទំនេរ ឬទីតាំងដែលអាចផ្លាស់ប្ដូរបាន។

ទីមួយ ទីតាំងដែលត្រូវបានចាត់ទុកថាជាដីសាធារណៈគួរតែត្រូវបានផ្ដល់អាទិភាពសម្រាប់ការផ្លាស់ប្ដូរ។ តំបន់ដែលស្ថិតនៅក្រោមស្ពានអាកាសជាទូទៅ គឺជាទីធ្លាទំនេរទុកចោល ផ្លូវលំ និងតំបន់ ដែលនៅជាប់នឹងប្រឡាយក៏គួរតែត្រូវបានកំណត់គោលដៅផងដែរ។

ខេត្តសៀមរាបបានបង្ហាញរួចហើយ ពីយុទ្ធសាស្ត្រ និងផលវិជ្ជមាននៃការកែលម្អប្រឡាយទឹកស្អុយហូរកាត់សហគមន៍ក្រីក្រឱ្យក្លាយទៅជាសួនសាធារណៈបៃតង។ កាធ្វើបែបនេះបានពង្រីកទីធ្លាសាធារណៈនៅក្នុងទីក្រុងជាមួយនឹងការទទួលបានសួនសាធារណៈថ្មីមួយនេះ និងផ្លូវថ្មើរជើងផងដែរ។ សួនសាធារណៈដែលស្ថិតនៅលើប្រឡាយទឹកមានផ្លូវសម្រាប់ថ្មើរជើង និងលាតសន្ធឹងប្រវែង ៦២៥ ម៉ែត្រ ពីផ្លូវជាតិលេខ៦ ដល់ផ្លូវ សម្ដេចព្រះមហាសង្ឃរាជទេពវង្ស។

មិនត្រឹមតែប៉ុណ្ណោះ សហគមន៍ក្រីក្រក៏អាចធ្វើការរួមគ្នាដើម្បីផ្លាស់ប្ដូរជាបណ្ដោះអាសន្ននូវដីឯកជនដែលនៅទំនេរ។ ទោះបីជាវាពិបាកជាងកែលម្អទីធ្លាសាធារណៈ ដែលមានស្រាប់ក៏ដោយ ប៉ុន្តែអត្ថប្រយោជន៍នៃទីធ្លាសាធារណៈអាចជំរុញសហគមន៍មួយដើម្បីបញ្ចុះបញ្ចូលម្ចាស់ដីឱ្យទទួលយកនូវគំនិតផ្ដួចផ្ដើមបែបនេះក្នុងរយៈពេលខ្លីទៅមធ្យម។

យ៉ាងណាមិញ ម្ចាស់ដីក៏អាចទទួលបានផលប្រយោជន៍ នៅពេលដែលដីរបស់ពួកគេ ត្រូវបានប្រើប្រាស់ជាកន្លែងសាធារណៈដ៏រស់រវើក។ ឧទាហរណ៍ ពួកគេទទួលបានអត្ថប្រយោជន៍ពីការបង់ពន្ធលើអចលនទ្រព្យទាបពីព្រោះដីរបស់ពួកគេមិនត្រូវបានចាត់ទុកថាជាដីទំនេរទៀតទេ។ លើសពីនេះ ពួកគេប្រហែលជាអាចជួលតូបសម្រាប់អ្នកលក់ជាផ្នែកនៃការរៀបចំផងដែរ។

ទីពីរ ការធ្វើអន្តរាគមន៍លើទីធ្លាសាធារណៈខ្នាតធំ ទោះបីពិបាកជាងនេះក៏ដោយ ក៏នៅតែអាចសម្រេចបាន ប្រសិនបើដីទំនេរអាចរកបាននោះ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ ទីក្រុងភ្នំពេញបានផ្លាស់ទីកន្លែងឧស្សាហកម្មមួយចំនួន ឱ្យនៅតាមជាយក្រុង ឬខេត្តវិញ នេះគឺជាឱកាសដើម្បីអភិវឌ្ឍន៍ និងកែប្រែអតីតតំបន់ឧស្សាហកម្មឱ្យបំពេញតម្រូវការផ្សេងៗឡើងវិញ។

សួនសាធារណៈហួតាន (Houtan) ទីក្រុងសៀងហៃ ផ្តល់នូវឧទាហរណ៍ដ៏ល្អមួយសម្រាប់ការអភិវឌ្ឍឡើងវិញនៃអតីតតំបន់ឧស្សាហកម្ម។ ទីធ្លាសាធារណៈនេះបានស្តារផ្នែកមួយនៃមាត់ទន្លេហាងពូ (Huangpu) ដោយបានរៀបចំឡើងវិញនូវ រោងម៉ាស៊ីនដែក កន្លែងចាក់សំរាម និងកន្លែងផលិតកប៉ាល់ ឱ្យក្លាយទៅជាតំបន់ឧទ្យានបៃតង។ វារួមបញ្ចូលផ្លូវដើរមើលទិដ្ឋភាពទេសភាពតាមដងទន្លេ និងប្រព័ន្ធ អេកូឡូស៊ីតំបន់ដីសើមធម្មជាតិ។ ស្របពេលជាមួយគ្នានេះដែរ ទីធ្លាសាធារណៈនេះក៏ដើរតួនាទីជាហេដ្ឋារចនាសម្ព័ន្ធចម្រោះទឹកធម្មជាតិ គឺចម្រោះទឹកកខ្វក់ ១ ៩០០ម៉ែត្រគូប ជារៀងរាល់ថ្ងៃ។

**ទីធ្លាសាធារណៈ**

សហគមន៍ក្រីក្រមួយអាចទទួលបានអត្ថប្រយោជន៍ពី សង្គម សុខភាព បរិស្ថាន និងសេដ្ឋកិច្ចពីការដាក់បញ្ចូលសួនសាធារណៈខ្នាតតូច។ ជាពិសេសសម្រាប់សហគមន៍ក្រីក្រ ដែលជួបការលំបាកក្នុងការអាចទទួលបានអត្ថប្រយោជន៍ពីការបង្កើនអារម្មណ៍សុវត្ថិភាពក្នុងសង្គម និងអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៅពេលដែលបានបង្កើតទីធ្លាសាធារណៈ។

ការបង្កើនទីធ្លាសាធារណៈបៃតងបែបនេះ មិនត្រឹមតែអាចអនុវត្តបានច្រើនជាង បើធៀបនឹងទីធ្លាសាធារណៈធំៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចមានភាពបត់បែនជាង សម្រាប់សហគមន៍ក្រីក្រ និង អ្នកប្រើប្រាស់ទាំងអស់ផងដែរ។ អ្នករៀបចំផែនការទីក្រុង និងអាជ្ញាធរមូលដ្ឋានគួរតែធ្វើការជាមួយប្រជាជន ឬសហគមន៍ក្រីក្រ ដើម្បីប្រែក្លាយដីទំនេរទៅជាដីដែលបំរើប្រយោជន៍ដល់សាធារណៈ។

**អត្ថបទសិក្សាស្រាវជ្រាវខ្លីខាងលើនេះ ឆ្លុះបញ្ចាំងពីជាទស្សនៈរបស់អ្នក**
**ស្រាវជ្រាវវ័យក្មេងលើជ្រុងមួយនៃការអភិវឌ្ឍន៍ក្រោមប្រធានបទ៖**
**" សួនសាធារណៈនៅក្នុងទីក្រុង តែជាកន្លែងមួយដែលផ្សារភ្ជាប់**
**ទំនាក់ទំនងមនុស្សក្នុងសង្គម"**

**បញ្ជាក់អត្ថបទនេះ មិនបានសិក្សាស្រាវជ្រាវស៊ីជម្រៅ និងឆ្លុះបញ្ចាំងអំពី*
*ទស្សនៈរបស់អង្គការសមាគមធាងត្នោត (ស.ធ.ត)។*